**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
# ស្តីពី
# សិក្ខាសាលាពិគ្រោះយោបល់ត្រីភាគីស្តីពីការធ្វើវិសោធនកម្មច្បាប់ស្តីពីការងារ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនសាធារណជន មេត្តាជ្រាបថា នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០ នេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនឹងរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាលក្ខណៈត្រីភាគីស្តីពី "**ការធ្វើវិសោធនកម្មច្បាប់ស្តីពីការងារ**" ដោយមានជំនួយបច្ចេកទេសពីអង្គការអន្តរជាតិខាងការងារ(ILO) នៅសណ្ឋាគារសាន់វេ រាជធានីភ្នំពេញ។ សិក្ខាសាលាពិគ្រោះយោបល់ដែលមានការចូលរួមពីតំណាងភាគីសហជីពចំនួន ១៨រូប តំណាងភាគីនិយោជកចំនួន ១៧រូប និងដៃគូរបស់ក្រសួងចំនួន ១១រូប នេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណង ដើម្បីពិភាក្សាអំពីៈ

១-ការកែសម្រួលបទប្បញ្ញត្តិពាក់ព័ន្ធនឹងវេនការងាររបស់រោងចក្រ សហគ្រាស គ្រឹះស្ថាន ដែលមានដំណើរការលើសពី ១វេនជាប្រចាំ។ ការកែសម្រួលនេះ គឺដើម្បីបង្កើនភាពទាក់ទាញឧស្សាហកម្មទំនើបដូចជា រោងចក្រផលិតបរិក្ខារអគ្គិសនី គ្រឿងអេឡិចត្រូនិច និងការកែច្នៃម្ហូបអាហារ ជាដើម និងបង្កើនការងារជូនប្រជាពលរដ្ឋ។ ដោយឡែក រោងចក្រ សហគ្រាស គ្រឹះស្ថាន ដែលធ្វើការលើសពី ១វេនម្តងម្កាល គឺនៅបន្តអនុវត្តបទប្បញ្ញត្តិដែលមានជាធរមាន។

២-ការពង្រីកវិសាលភាពសេវាកម្មរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងការដោះស្រាយវិវាទបុគ្គល ដើម្បីពង្រឹងប្រសិទ្ធភាពនៃយន្តការដោះស្រាយវិវាទការងារ និងឆ្លើយតបនឹងតម្រូវការរបស់ភាគីវិវាទ ព្រមទាំងកាន់តែធានាបាននូវសុខដុមរមនាក្នុងទំនាក់ទំនងវិជ្ជាជីវៈ។

៣-ការលុបការឈប់នៅថ្ងៃបន្ទាប់សម្រាប់ថ្ងៃឈប់សម្រាកបុណ្យចំថ្ងៃអាទិត្យ ដើម្បីឆ្លើយតបទៅនឹងការវិវឌ្ឍផ្នែកសង្គម-សេដ្ឋកិច្ចកម្ពុជា សំដៅលើកកម្ពស់ផលិតភាពការងារ និងពង្រឹងភាពប្រកួតប្រជែងសេដ្ឋកិច្ចកម្ពុជាទាំងក្នុងតំបន់ និងសកលលោក។

សិក្ខាសាលាពិគ្រោះយោបល់លើកទី១ នេះ នឹងផ្តល់ឱកាសដល់ភាគីពាក់ព័ន្ធក្នុងការពិនិត្យនិងពិភាក្សាផ្តល់ធាតុចូលនានា សំដៅការពារផលប្រយោជន៍បងប្អូនកម្មករនិយោជិត និងនិយោជក។ ក្រសួងនឹងបន្តសហការជាមួយដៃគូពាក់ព័ន្ធ ជាពិសេសអង្គការ ILO រៀបចំសិក្ខាសាលាពិគ្រោះយោបល់ និងកិច្ចប្រជុំពិគ្រោះយោបល់ជាលក្ខណៈត្រីភាគីបន្តទៀត ដើម្បីបន្តប្រមូលធាតុចូលពីគ្រប់ភាគីពាក់ព័ន្ធ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ជ្រាបជាព័ត៌មាន។

ថ្ងៃចន្ទ ៤រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩